រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

001KH01A-01

ការធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

១

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រទានព្រះពរដល់ការសិក្សានេះ ។

អានកិច្ចការ ១៦:២២-៣៥ ។

☐ គួសសញ្ញា «✓» នេះ ក្នុងប្រអប់ «☐» នេះ ពេលអ្នកបានអានរួចហើយ ។

តើយើងធ្វើពិធីជ្រមុជទឹក ដោយអំណាចអ្វី ?

ព្រះអម្ចាស់យេស៊ូគ្រីស្តរបស់យើង បង្គាប់យើងអោយធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មីទាំងអស់ ។

យោងទៅតាមម៉ាថាយ ២៨:១៨-២០ តើព្រះអម្ចាស់យេស៊ូបង្គាប់អោយយើងធ្វើពិធីជ្រមុជទឹក ដោយសារអំណាចកិរិតណា ? (សូមអានខទាំងនេះ) ។

_____

កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

ព្រះយេស៊ូបានទទួលគ្រប់អំណាចទាំងនៅលើស្ថានបរមសុខ ទាំងនៅលើផែនដី ពីព្រះជាម្ចាស់ជាព្រះបិតា ។ ហើយជាពិសេសព្រះអង្គមានអំណាចលើក្រុមជំនុំរបស់ព្រះអង្គ គឺយើងរាល់គ្នានេះឯង ។ យើងស្តាប់តាមព្រះអង្គ ព្រមទាំងស្រឡាញ់ព្រះអង្គ ដែលជាចៅហ្វាយដ៏ធំបំផុត និងជាមហាក្សត្ររបស់យើង ។

នៅពេលដែលពួកសាវ័កប្រកាសដំណឹងល្អ ពួកគេអំពាវនាវអោយបណ្តាជនកែប្រែចិត្តគំនិត ជឿ និងទទួលពិធីជ្រមុជទឹក ។ ហេតុនេះ យើងធ្វើពិធីជ្រមុជទឹកតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ និងតាមគំរូរបស់ពួកសាវ័កផងដែរ ។

ពិធីជ្រមុជទឹកជាការបញ្ជាក់ថា អ្នកមានជំនឿលើព្រះគ្រីស្ត បានទទួលការលើកលែងទោសអោយរួចពីអំពើបាប ហើយនិងថា អ្នកនោះបានរួមជាមួយព្រះគ្រីស្ត ។

កំណត់ចំណាំ : ក្រុមជំនុំផ្សេងៗរៀបចំធ្វើពិធីជ្រមុជទឹក តាមរបៀបផ្សេងៗគ្នា ។ សូមសំរួលការសិក្សានេះ តំរូវទៅតាមស្ថានភាពរបស់អ្នក ។



- នៅពេលដែលយើងផ្សព្វផ្សាយដំណឹងល្អ ប្រាប់ក្រុមគ្រួសារទាំងមូលរបស់អ្នកជឿថ្មីណាម្នាក់ បើសិនជាក្នុងរយៈពេលពីរ ឬ បីខែ គ្រួសាររបស់អ្នកជឿថ្មីនោះមិនទាន់ជឿទេ សូមធ្វើពិធីជ្រមុជទឹកអោយអ្នកជឿថ្មីនោះចុះ ព្រោះការស្តាប់បង្គាប់របស់អ្នកនោះ នឹងមានលទ្ធផលល្អ ។

- ធ្វើពិធីជ្រមុជទឹក (ឬជួយធ្វើពិធីជ្រមុជទឹក) អោយពួកអ្នកដែលកែប្រែចិត្តគំនិត ។ ចំពោះពួកអ្នកដែលបានទទួលពិធីជ្រមុជទឹករួចហើយ តែក្រោយមក បានងាកចេញពីព្រះជាម្ចាស់ បើសិនជាពួកគេសារភាព កែប្រែចិត្តគំនិត និងទទួលជឿវិញ សូមទទួលពួកគេឱ្យចូលរួមក្នុងក្រុមជំនុំវិញ ស្របទៅតាមរបៀបរបបរបស់ក្រុមជំនុំអ្នកចុះ ។

- សរសេរឈ្មោះសមាជិកក្រុមជំនុំក្នុងសៀវភៅបញ្ជីមួយ (ឬតែងតាំងលេខាម្នាក់អោយធ្វើការនេះ) ។ កត់ត្រាថ្ងៃខែដែលម្នាក់ៗទទួលពិធីជ្រមុជទឹកដែរ ។ រក្សាទុកបញ្ជីឈ្មោះនេះ ។

- ក្រោយពេលដែលពួកអ្នកជឿថ្មីបានទទួលពិធីជ្រមុជទឹកហើយ ការល្អ គីអោយពួកគេចាប់ផ្តើមចូលរួមធ្វើពិធីកាច់នំបុ័ង ។

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានទូលសូមអោយពួកអ្នកជឿថ្មីបានទទួលពិធីជ្រមុជទឹក និងបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ។
- សរសេរឈ្មោះពួកអ្នកជឿថ្មីនៅក្នុងក្រុមជំនុំរបស់អ្នក ដែលគួរទទួលពិធីជ្រមុជទឹក ។

_____

_____

_____

- ផ្សព្វផ្សាយដំណឹងល្អដល់ក្រុមគ្រួសាររបស់ពួកអ្នកជឿថ្មី ដើម្បីអោយពួកគេអាចថ្វាយខ្លួន និងទទួលពិធីជ្រមុជទឹករួមគ្នា ។ សរសេរឈ្មោះសមាជិកគ្រួសារទាំងនោះ ដែលអ្នកបានទៅលេង ។

_____

_____

_____

ហេតុអ្វីបានជាយើងធ្វើពិធីជ្រមុជទឹក ?

ពិធីជ្រមុជទឹកជានិមិត្តរូបបង្ហាញថា មនុស្សម្នាក់បានក្លាយជាកូនរបស់ព្រះអម្ចាស់យេស៊ូគ្រីស្តហើយ ។ នៅពេលដែលមនុស្សម្នាក់កែប្រែចិត្តគំនិត និង ជឿហើយ តើអ្នកនោះនឹងបានទទួលអ្វីយោងទៅតាមកិច្ចការ ២:៣៨ ?

_____

១- ព្រះជាម្ចាស់_____ទោសអោយរួចពី_____។

២- អំណោយទានជាព្រះវិ_____។

បន្ទាប់ពីកែប្រែចិត្តគំនិត អ្នកជឿទទួលពិធីជ្រមុជទឹក ទុកជាការប្រកាសអំពីជំនឿរបស់ខ្លួនលើព្រះគ្រីស្ត ។

យោងទៅតាមរ៉ូម ៦:១-៥ យើងស្លាប់ និងរស់ឡើងវិញរួមជាមួយព្រះគ្រីស្ត ដោយសារពិធីជ្រមុជទឹក តើយើងស្លាប់ខាងផ្នែកណា ?

_____

(ខ ២, សូមមើល អក្សរ «អ »ដែលពន្យល់នៅខាងក្រោមទំព័ររបស់ព្រះគម្ពីរ) ។

តើការស្លាប់ និងការរស់ឡើងវិញរួមជាមួយព្រះគ្រីស្ត មានគោល-ដៅដូចម្តេច ? (ខ ៤)

តើយើងធ្វើពិធីជ្រមុជទឹកអោយនរណា ?

នៅក្នុងកិច្ចការ ២:៣៦-៤២ និង ១០:៤៧-៤៨ លោកពេត្រុសបង្គាប់អោយធ្វើពិធីជ្រមុជទឹកអោយគ្រប់អ្នកជឿថ្មី ដែលសារភាពកែប្រែចិត្តគំនិត ។ យោងទៅតាមកិច្ចការ ២:៣៨ តើពួកអ្នកទាំងនោះត្រូវធ្វើអ្វី ដើម្បីអាចទទួលពិធីជ្រមុជទឹកបាន ?

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើអ្នកណាបង្គាប់យើងអោយធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី ?

២- ពិធីជ្រមុជទឹកបញ្ជាក់ថា យើងបានរួមជាមួយ :

☐ គ្រួគង្វាល ។

☐ ព្រះគ្រីស្ត ។

៣- យើងធ្វើពិធីជ្រមុជទឹកដើម្បី :

☐ ស្តាប់តាមបង្គាប់របស់ព្រះគ្រីស្ត និងផ្តល់ឱកាសអោយពួកអ្នកជឿថ្មី ប្រកាសជាសាធារណៈអំពីជំនឿរបស់ពួកគេលើព្រះគ្រីស្ត និងការដែលព្រះអង្គបានលើកលែងទោសអំពើបាបពួកគេ ។

☐ បង្ហាញថា អ្នកជឿជាគ្រីស្តជនគ្រប់លក្ខណៈហើយ ។

ក្នុងព្រះនាមព្រះជាម្ចាស់ ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

- ម៉ាថាយ ២៨:១៩ ។
- កិច្ចការ ២:៣៨ ។
- រ៉ូម ៦:១-១៤ ។
- ១ កូរិនថូស ១២:១២-១៣ ។

កំណត់ចំណាំ : ទាក់ទងជាមួយគ្រូបង្ហាត់កិច្ចការឃ្វាលរបស់អ្នក អំពីរបៀបធ្វើពិធីជ្រមុជទឹករបស់ក្រុមជំនុំអ្នក ។

កំណត់ចំណាំ :

យើងមិនមែនធ្វើពិធីជ្រមុជទឹកឱ្យពួកអ្នក ដែលគ្រាន់តែលើកដៃនៅពេលដែលយើងសុំអញ្ជើញពួកគេ ក្រោយការអធិប្បាយនៅថ្ងៃអាទិត្យ ឬ នៅពេលប្រជុំណាមួយទៀតទេ ។ ការលើកដៃគ្រាន់តែជាកាយវិការខាងក្រៅ មិនទាន់មានន័យថាគេជឿដោយស្មោះអស់ពីចិត្តគំនិតនោះទេ ។ អ្នកទាំងនោះ ត្រូវប្រកាសពីការកែប្រែចិត្តគំនិត និងពីជំនឿរបស់ខ្លួនលើព្រះគ្រីស្តទៀត ។ បន្ទាប់មក ទើបយើងធ្វើពិធីជ្រមុជទឹកអោយពួកគេទុកជាការបញ្ជាក់ថា ពួកគេត្រូវបានព្រះជាម្ចាស់លើកលែងទោសអោយរួចពីបាប ហើយបានចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់ហើយ ។



សូមប្រើវគ្គព្រះគម្ពីរទាំងនេះ ដើម្បីណែនាំអ្នកក្នុងការបង្ហាត់បង្រៀនអំពីការធ្វើពិធីជ្រមុជទឹក :

កិច្ចការ ៨:១២	កិច្ចការ ១៦:១៣-១៥
កិច្ចការ ៨:២៦-៤០	កិច្ចការ ១៦:៣១-៣៤
កិច្ចការ ៩:១៧-១៩	កិច្ចការ ១៩:១-៧
កិច្ចការ ១០:២៣-៤៨	

តើយើងធ្វើពិធីជ្រមុជទឹកអោយអ្នកជឿថ្មី នៅពេលណា ?

យោងទៅតាមកិច្ចការ ២:៤១ បន្ទាប់ពីថ្វាយខ្លួនហើយ តើអ្នកជឿថ្មីត្រូវទទួលពិធីជ្រមុជទឹកនៅពេលណា ?

អានកិច្ចការ ១៦:២៥-៣៥ : តើពួកអ្នកជឿថ្មីទទួលពិធីជ្រមុជទឹកនៅពេលណា ? (សូមប្រៀបធៀប ខ២៥ ជាមួយ ខ៣៣)។

រយៈពេលពីរបីខែ ក្រោយពេលដែលអ្នកជឿថ្មីបានទទួលពិធីជ្រមុជទឹក និងចូលរួមក្នុងក្រុមជំនុំហើយ ជាពេលវេលាសំខាន់សំរាប់ឱ្យពួកគេរីកចំរើនឡើងខាងព្រលឹងវិញ្ញាណ ។ នៅពេលនោះហើយដែលគេបង្កើតគ្រឹះខាងជំនឿ លក្ខណៈជាគ្រីស្តជន និងគ្រឹះសំរាប់ធ្វើខ្លួនអោយក្លាយជាសាវ័ក ដែលចេះស្តាប់តាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ។ សូមបង្រៀនគេឱ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលព្រះអម្ចាស់យេស៊ូគ្រីស្តបង្គាប់ ។

តើយើងធ្វើពិធីជ្រមុជទឹក ដោយរបៀបណា ?

ដោយជ្រមុជទៅក្នុងទឹក ទុកជានិមិត្តរូបអំពី :

- ការលាងជំរះអំពើបាប ។ (កិច្ចការ ២២:១៦)
- ការរួមជាមួយព្រះគ្រីស្ត ដែលសុគត និងមានព្រះជន្មឡើងវិញ ។
- ការទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ។
- ការចូលរួមក្នុងព្រះកាយព្រះគ្រីស្ត ដែលជាក្រុមជំនុំជាព្រះ-សហគមន៍ ។

ពួកអ្នកដែលបានទទួលជឿដំណឹងល្អ ទទួលពិធីជ្រមុជទឹក នៅថ្ងៃដែលពួកគេទទួលជឿដំណឹងល្អនោះ ។ ពួកសាវ័ក បានប្រកាសដំណឹងល្អប្រាប់បណ្តាជន ។ បន្ទាប់មក ពួកសាវ័កបានធ្វើពិធីជ្រមុជទឹកអោយពួកអ្នក ដែលថ្វាយ ខ្លួនទាំងនោះ ។



បន្ទាប់ពីថ្វាយខ្លួនភ្លាម លោកប៉ូលងងឹតភ្នែក មើលអ្វីមិនឃើញ និងអត់ទទួលទានអាហារបីថ្ងៃ ។ សូមអានកិច្ចការ ៩:១៧-១៩ ។ តើលោកប៉ូលទទួលពិធីជ្រមុជទឹកនៅពេលណា គឺមុនពេល ដែលគាត់ទទួលទានអាហារវិញ ឬ ក៏ក្រោយ ?

ពីធីជ្រមុជទឹកជាសញ្ញាសំគាល់ថា យើងបានស្លាប់ពីអំពើបាប ។ *«យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ ។ ដូច្នេះ ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ ដោយសិរីរុងរឿងរបស់ព្រះបិតា យ៉ាងណា យើងក៏រស់តាមរបៀបថ្មីយ៉ាងនេះដែរ »* (រ៉ូម ៦:៤)។

បើសិនជាយើងមិនធ្វើពិធីជ្រមុជទឹកអោយមនុស្សម្នាក់ ដែលជឿ អស់ពីចិត្តលើព្រះគ្រីស្តនោះ បានន័យថា យើងមិនស្តាប់បង្គាប់ ហើយ ។ បើយើងពន្យារពេលធ្វើពិធីជ្រមុជទឹកអោយពួកអ្នកទើប នឹងកើតជាថ្មីខាងជំនឿនោះ ការសង្ស័យមិនទុកចិត្តរបស់យើង ធ្វើ អោយគេអាចជំពប់ហើយ ។ ពួកអ្នកជឿថ្មីអាចគិតថា ពួកគេនៅ ខ្វះអ្វីម៉្យាង មិនទាន់អាចក្លាយជាអ្នកជឿបាន ។

បើធ្វើពិធីជ្រមុជទឹកអោយអ្នកជឿ ដែលចង់ទទួលពិធីជ្រមុជទឹក ទាំងអស់ ទោះជាអាចមានអ្នកជឿក្លែងក្លាយ ដែលឆ្លៀតរកផល ប្រយោជន៍ក្នុងចំណោមពួកគេក៏ដោយ នោះប្រសើរជាងបដិសេធ មិនធ្វើពិធីជ្រមុជទឹកឱ្យអ្នកជឿពិតជាច្រើន ដែលនៅក្នុងចំណោម ពួកគេ ។ ឧទាហរណ៍ : ពួកសាវ័កមិនបានបដិសេធមិនធ្វើពិធី ជ្រមុជទឹកអោយមនុស្សបីពាន់នាក់នៅក្រុងយេរូសាឡិម ដោយ សារតែខ្លាចថា នៅក្នុងចំណោមពួកគេមានមនុស្សដូចជាអាណា-ញ៉ាស និងសាភីរ៉ានោះទេ (កិច្ចការ ៥:១-១១) ។

បន្ទាប់ពីបណ្តាជនបានកែប្រែចិត្តគំនិត និងទទួលជឿហើយ ពួកសាវ័កតែងតែធ្វើពិធីជ្រមុជទឹកឲ្យបណ្តាជនភ្លាមៗ ហើយបើមានឱកាស ពួកសាវ័កផ្សាយដំណឹងល្អប្រាប់ដល់ក្រុមគ្រួសាររបស់ពួកគេទៀត (កិច្ចការ ១៦:៣១-៣៣) ។



ជ្រមុជទឹករួចមក យើងត្រូវឆាប់ណែនាំគេអោយទាក់ទងសមប្រកបជាមួយព្រះគ្រីស្ត និងអ្នកជឿឯទៀត ។

យើងអញ្ជើញគេអោយចូលជាសមាជិកក្រុមជំនុំ និងបង្រៀនគេឱ្យក្លាយជាសាវ័ក តាមកម្មវិធីបង្កើតសាវ័ក ក្រោយពេលដែលគេទទួលពិធីជ្រមុជទឹកហើយភ្លាម ។ បន្ទាប់មក គេនឹងរីកចំរើនជាចាស់ទុំខាងព្រលឹងវិញ្ញាណ ហើយជីវិតគេនឹងវិសុទ្ធបន្តិចម្តងៗ ។

មិនត្រូវ :



អ្នកជឿថ្មីខិតខំធ្វើខ្លួនអោយបរិសុទ្ធដោយខ្លួនឯងសិន មុននឹងចូលរួមក្នុងក្រុមជំនុំ ។



អ្នកជឿថ្មីរីកចំរើនខាងព្រលឹងវិញ្ញាណ
និងបានបរិសុទ្ធកាន់តែខ្លាំងឡើង
នៅក្នុងក្រុមជំនុំ/ព្រះសហគមន៍ ។

ទារកដែលទើបនឹងកើត ត្រូវការអោយមនុស្សធំជួយគ្រប់យ៉ាង យ៉ាងណា អ្នកជឿថ្មី ក៏ត្រូវការអោយយើងជួយគេគ្រប់យ៉ាង យ៉ាងនោះដែរ ។ ក្រោយពេលដែលអ្នកជឿថ្មីបានទទួលពិធី

នៅក្នុងព្រះគម្ពីរ ពួកអ្នកជឿច្រើនតែទទួលពិធីជ្រមុជទឹកភ្លាមៗ ឧទាហរណ៍ ដូចជាលោកគ័រនេលាូស និងគ្រួសាររបស់គាត់ (កិច្ចការ ១០:២៤-៤៨) និងជនជាតិអេត្យូពី (កិច្ចការ ៨:២៦-៣៩) ។

តាមធម្មតា បន្ទាប់ពីអ្នកជឿថ្មីថ្វាយខ្លួនរួចហើយ គេត្រូវទទួលពិធីជ្រមុជទឹកយ៉ាងឆាប់បំផុត ។ ពួកអ្នកជឿថ្មីនោះ មិនចាំបាច់រង់ចាំបញ្ចប់ការសិក្សារយៈពេលវែងមួយរួច ទើបអាចទទួលពិធីជ្រមុជទឹកនោះបានទេ ។ ការបង្រៀនពួកគេអោយក្លាយជាសាវ័ក ត្រូវធ្វើនៅក្រោយពេលដែលគេទទួលពិធីជ្រមុជទឹក ។ (នៅប្រទេសកម្ពុជា មនុស្សខ្លះចង់ទទួលពិធីជ្រមុជទឹក ដោយសារមូលហេតុខុសឆ្គង ឬ មុនពេលសមល្មមអាចទទួលពិធីជ្រមុជទឹកបាន ។ ជួនកាល មនុស្សចង់ទទួលពិធីជ្រមុជទឹក ព្រោះចង់ក្លាយជាសមាជិករបស់សាសនាបរទេសមួយ ឬ ចង់បានផលប្រយោជន៍ពីពិធីនោះ ឬ ចង់ទទួលអំណាចសក្តិសិទ្ធិ តាមរយៈពិធីជ្រមុជទឹក ឬ ចង់បំពេញចិត្តមិត្តភ័ក្តិ ។ ដូច្នេះ សំខាន់បំផុត គឺត្រូវឱ្យអ្នកដែលត្រូវទទួលពិធីជ្រមុជទឹក មានឱកាសអាចយល់ និងយល់ស្របនឹងគោលជំនឿជាមូលដ្ឋានរបស់ដំណឹងល្អ ដូចជា : ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូ ជំនឿលើព្រះយេស៊ូ ការកែប្រែចិត្តគំនិតចេញពីអំពើបាប និងការលើកលែងទោសអំពើបាប) ។

តើយើងត្រូវរៀបចំមនុស្សសំរាប់ទទួល ពិធីជ្រមុជទឹក ដោយរបៀបណា ?

អ្នកដែលទទួលពិធីជ្រមុជទឹកបាន គឺអ្នកដែលបានកែប្រែចិត្តគំនិតចេញពីអំពើបាបរបស់ខ្លួន និងជឿលើព្រះអម្ចាស់យេស៊ូគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ។ ព្រះគម្ពីរធ្វើអោយគេដឹងជាក់ថា គេបានជ្រះស្អាតពីអំពើបាបរបស់គេ ដោយសារគេជឿលើព្រះយេស៊ូគ្រីស្ត ។ ក្រុមជំនុំត្រូវធ្វើពិធីជ្រមុជទឹកអោយគេ ដើម្បីបញ្ជាក់អំពីជំនឿរបស់គេលើព្រះគ្រីស្ត និងដើម្បីបញ្ជាក់ថា ព្រះអម្ចាស់ពិតជាលើកលែងទោសអំពើបាបអោយគេមែន ។ ដូច្នេះ ពិធីជ្រមុជទឹកមានពីរផ្នែក :

សេចក្តីដែលអ្នកជឿថ្មីត្រូវធ្វើ :

- កែប្រែចិត្តគំនិតពីអំពើបាបរបស់ខ្លួន ។ (កិច្ចការ ២:៣៨)
- មានជំនឿលើព្រះគ្រីស្ត ។ (ម៉ាកុស ១:១៥)

កិច្ចការដែលក្រុមជំនុំត្រូវធ្វើ :

- ធ្វើអោយអ្នកជឿថ្មីដឹងជាក់ថា ព្រះជាម្ចាស់លើកលែងទោសអំពើបាបរបស់គេ ។ (លូកា ២៤:៤៥-៤៨)

ក្រោយពីធ្វើពិធីជ្រមុជទឹករួច តើយើងនឹងបាន វិសុទ្ធកាន់តែខ្លាំងឡើងៗ ដោយរបៀបណា ?

យោងទៅតាមរបៀបរបបរបស់ពួកសាវ័ក ការទទួលពិធីជ្រមុជទឹកជាជំហានទីមួយនៃការបង្ហាញពីជំនឿ និង ការប្រតិបត្តិតាមព្រះ-ជាម្ចាស់ ។ ក្រោយពីបានទទួលពិធីជ្រមុជទឹកហើយ អ្នកជឿថ្មីបន្តរីកចំរើនក្នុងជំនឿ និង កាន់តែប្រតិបត្តិតាមព្រះជាម្ចាស់ថែមទៀត ។ អ្នកជឿអាចរីកចំរើនក្នុងក្រុមជំនុំ ដោយសារគ្រូគង្វាល និងអ្នកជឿឯទៀតជួយណែនាំ និង បង្រៀនគេ ។ ពិធីជ្រមុជទឹកមិនមែនជាពិធីសំរាប់ធ្វើឱ្យបានបរិសុទ្ធទេ តែជាមធ្យោបាយសំរាប់អោយអ្នកជឿថ្មីប្រកាសថា គេបានសង្គ្រោះរួចពីអំពើបាបហើយដោយសារព្រះយេស៊ូគ្រីស្ត ហើយគេនឹងបន្តពឹងផ្អែកលើព្រះ-វិញ្ញាណដ៏វិសុទ្ធ ដើម្បីអោយព្រះអង្គកែឆ្នៃគេអោយបានដូចជាព្រះគ្រីស្ត (២ កូរិនថូស ៣:១៨) ។

© Project WorldReach © SEAN



- ធ្វើពិធីជ្រមុជទឹកអោយអ្នកជឿថ្មីនោះ ។ (ម៉ាថាយ ២៨:១៨-២០, កិច្ចការ ២:៣៨-៤២)

- អធិស្ឋានទូលសូមអោយអ្នកនោះដើរតាមព្រះគ្រីស្តប្រកបដោយជោគជ័យ ដោយសារទ្វានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ (កិច្ចការ ៨:១២-១៧) ។

បន្ទាប់មក ក្រុមជំនុំត្រូវបង្រៀនអ្នកនោះ អោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះគ្រីស្ត ។ (ម៉ាថាយ ២៨:១៨-២០)

តើពិធីជ្រមុជទឹកធ្វើអោយយើងបានរួមជាមួយនរណា ?

ពិធីជ្រមុជទឹកជានិមិត្តរូបតំណាងថា យើងបានរួមជាមួយនឹងព្រះ-អម្ចាស់យេស៊ូគ្រីស្ត និងជាមួយពួកអ្នកជឿទាំងអស់ ។ ពិធីជ្រមុជទឹកផ្តល់ឱកាសឱ្យអ្នកជឿបង្ហាញអំពីជំនឿរបស់ខ្លួនដល់អ្នកដទៃ ។ លោកភីលីពធ្វើពិធីជ្រមុជទឹកជូនមន្ត្រីជាតិអេត្យូពី នៅក្នុងវាលរហោដ្ឋាន ឆ្ងាយដាច់សង្វែងពីក្រុមជំនុំ និង អ្នកជឿឯទៀត ។ នៅពេលនោះ មានតែលោកភីលីព មន្ត្រីជាតិអេត្យូពី និង អ្នកបំរើរបស់មន្ត្រីនោះប៉ុណ្ណោះ ។ ប៉ុន្តែ ចាប់ពីពេលដែលមន្ត្រីនោះកែប្រែចិត្តគំនិតជឿ និង ទទួលពិធីជ្រមុជទឹក គាត់បានចូលរួម

ជាមួយព្រះគ្រីស្ត និង អ្នកជឿគ្រប់ជំនាន់ទាំងអស់របស់ព្រះ-
សហគមននៃសកលលោកទាំងមូលដែរ ។ យោងទៅតាម កូឡូស
២:១១-១៣ យើងត្រូវបានកប់រួមជាមួយនឹងព្រះគ្រីស្ត គឺជីវិត
ពេញដោយអំពើបាបបានកន្លងផុតទៅ ហើយត្រូវរស់ឡើងវិញ
ជាមួយព្រះអង្គ គឺជីវិតថ្មីរបស់យើងក្នុងព្រះគ្រីស្តចាប់ផ្តើមឡើង
ដោយសារជំនឿរបស់យើង ។ ដូចនេះ យើងជាអ្នកជឿបានរួម
ជាមួយព្រះគ្រីស្ត ព្រមទាំងជាមួយព្រះសហគមន៍នៃសកលលោក
ទាំងមូល តាមរយៈព្រះអង្គ ។



ដោយសារព្រះបន្ទូលព្រះជាម្ចាស់ យើងបានផ្តល់សក្ខីភាពអំពី
ព្រះយេស៊ូថា អស់អ្នកដែលជឿលើព្រះអង្គ នឹងទទួលការលើក
លែងទោសអោយរួចពីបាប និងទទួលការសង្គ្រោះអស់កល្ប
តាមរយៈព្រះយេស៊ូគ្រីស្ត (កិច្ចការ ១០:៤៣) ។

ដោយសារពិធីជ្រមុជទឹក យើងបញ្ជាក់ថា អ្នកជឿថ្មីនោះបានរួម
ជាមួយព្រះគ្រីស្ត និងព្រះកាយរបស់ព្រះអង្គ ដែលជាក្រុមជំនុំ
ហើយ ។ យើងជឿទុកចិត្តថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នឹង
សំរេចកិច្ចការល្អ ដែលព្រះអង្គបានចាប់ផ្តើមធ្វើក្នុងចិត្តអ្នកនោះ
ហើយ ។



© Project WorldReach © SEAN